# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ព្រះសង្ឃសមណនិស្សិតខ្មែរ

website ៖ www.hoksavann.org

ថ្ងៃទី២៣ កក្កដា ២០០៩



ក្នុងព្រះត្រៃបិដកនៃគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនានិយាយថា ព្រះពុទ្ធសាសនាដែលស្ថិតនៅនិងលូតលាស់ចំរើន ដោយសារមានអ្នកសិក្សារៀនសូត្រឲ្យយល់ច្បាស់នូវធម៌វិន័យរបស់ព្រះពុទ្ធ ហើយប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ ។ នៅប្រទេសកម្ពុជាមានបង្កើតពុទ្ធិកសិក្សា ដើម្បីឲ្យព្រះសង្ឃសិក្សាធម៌វិន័យរបស់ព្រះពុទ្ធ ។ ការបណ្តុះធនធានព្រះសង្ឃឲ្យមានចំណេះដឹងផ្លូវលោកផ្លូវធម៌ជាអាទិភាពសំខាន់បំផុត ដើម្បីឲ្យព្រះពុទ្ធសាសនាស្ថិតស្ថេរនិងលូតលាស់ចំរើន ព្រោះព្រះសង្ឃជាភេទពិសេ-ស មានលទ្ធភាពច្រើនអាចផ្សព្វផ្សាយព្រះពុទ្ធសាសនាមានប្រសិទ្ធិភាពជាងគ្រហស្ថ ព្រោះគ្រហស្ថមានការរវល់បលិពោធ ធ្វើការរកស៊ីចិញ្ចឹមគ្រួសារ ។ មានគ្រហស្ថខ្លះបានសិក្សាធម៌វិន័យរបស់ព្រះពុទ្ធ បានយល់ច្បាស់តែមានចំនួនតិច ។ ដូច្នេះភេទព្រះសង្ឃជាភេទបរិសុទ្ធ ទើបមានលទ្ធភាពច្រើន អាចពង្រឹងនិងពង្រីកព្រះពុទ្ធសាសនារឹងមាំនិងរីកលូតលាស់ចំរើន ។

ចំពោះព្រះសង្ឃសមណសិស្សនិងសមណនិស្សិតខ្មែរដែលសិក្សានៅពុទ្ធិកសិក្សា មានការពិបាកខាងបច្ច័យ៤ ជាពិសេសបិណ្ឌបាត្របច្ច័យ ។ ព្រះសង្ឃនៅតាមស្រុកស្រែចំការ អាចនិមន្តបិណ្ឌបាត្របានស៊ើរគ្រប់កន្លែង ។ ចំណែកព្រះសង្ឃដែលមកសិក្សាក្នុងពុទ្ធិកមធ្យមសិក្សា និងពុ

ទិកឧត្តមសិក្សានៅទីក្រុងមានក្រុងភ្នំពេញជាដើម ពុំអាចនិមន្តបិណ្ឌបាត្រ បានគ្រប់អង្គឡើយ ព្រោះនៅទីក្រុងពុទ្ធបរិស័ទពុំសូវនិយមដាក់បាត្រព្រះសង្ឃទេ ។

ផុយពីប្រទេសកម្ពុជា នៅប្រទេសថៃនិងប្រទេសភូមា ទោះបីនៅស្រុកស្រែចំការក្តី នៅទីក្រុងក្តី ពុទ្ធបរិស័ទគេនិយមដាក់បាត្រព្រះសង្ឃដូចគ្នា ។ ដូច្នេះពុទ្ធបរិស័ទខ្មែរនៅទីក្រុង គួរពិចារណាឡើងវិញ គួរនាំគ្នាផ្តើមគំនិតដាក់បាត្រប្រគេនព្រះសង្ឃ ដើម្បីជាការលើកទឹកចិត្ត និងជាការជួយឧបត្ថម្ភព្រះសង្ឃ ឲ្យលោកសិក្សាបានដោយគ្មានឧបសគ្គ ។ ការជួយឧបត្ថម្ភព្រះសង្ឃដោយអាហារបិណ្ឌបាត្រក្តី ដោយសិក្ខូបករណ៍ក្តី គឺឧបករណ៍សិក្សាមានសៀវភៅជាដើមក្តី មិនត្រឹមតែបានបុណ្យកុសលច្រើនទេ ប៉ុន្តែជាការជួយបណ្តុះសមត្ថភាពរបស់ព្រះសង្ឃឲ្យបានគ្រប់គ្រាន់ ដើម្បីរក្សាការពារព្រះពុទ្ធសាសនាឲ្យបានគង់វង្សជានិរន្តរភាព ។ ទោះបីព្រះសង្ឃអង្គខ្លះបាននិមន្តទៅសិក្សានៅមហាវិទ្យាល័យនានាជាមួយនិស្សិតជាគ្រហស្ថក៏ដោយ ក៏ពុំមែនទាស់ខុសអ្វីឡើយ ព្រោះការសិក្សានោះនាំឲ្យព្រះសង្ឃចេះដឹងវិជ្ជាផ្លូវលោកផង ។

## អំពីព្រះសង្ឃពាក់ទ្រនាប់ជើង

ក្នុងព្រះវិន័យនិយាយថា ព្រះសង្ឃនិមន្តធ្វើធុតង្គក្នុងព្រៃត្រូវពាក់ទ្រនាប់ជើងពីពីរជាន់ទៅបួនជាន់ ។ ព្រះពុទ្ធានុញ្ញាតនេះ ដោយព្រះបំណងពេលព្រះសង្ឃដើរក្នុងព្រៃ បើជាន់បន្លាឬជាន់របស់ផ្សេងៗកុំឲ្យមុតដល់ព្រះបាទ ។ ក្រៅពីក្នុងព្រៃមិនឃើញអនុញ្ញាតដោយបែបណាទេ ប៉ុន្តែឃើញនិយាយថា ព្រះភិក្ខុសង្ឃពាក់ទ្រនាប់ជើងត្រូវអាបត្តិទុក្កដ ។ អាបត្តិទុក្កដនេះជាអាបត្តិតូចបំផុតក្នុងបណ្តាអាបត្តិទាំង៥កង ។ សម័យក្រោយ បើព្រះអង្គគង់នៅ ទតឃើញផលមិនល្អក្នុងការមិនពាក់ទ្រនាប់ជើង ព្រះអង្គនឹងអនុញ្ញាតឲ្យពាក់ពុំខានឡើយ ។ តាមការស្រាវជ្រាវវិជ្ជាពេទ្យថា នៅតាមដីតាមទឹកតាមអាកាស សុទ្ធតែមានមេរោគនៅគ្រប់ទីកន្លែង ជាពិសេសនៅតាមដី ។ បើជាន់ផ្ទាល់ដីមិនពាក់ទ្រនាប់ជើង មានមេរោគម៉្យាងចូលតាមស្បែកជើង នាំបណ្តាលឲ្យមានជម្ងឺ ។ ថ្នល់ចាក់កៅស៊ូនៅទីក្រុងភ្នំពេ

ញ ពេលរដូវក្ដៅមានកំដៅខ្លាំងណាស់ បើមិនពាក់ទ្រនាប់ជើងទេ បាតជើងនឹងត្រូវកំដៅយ៉ាងខ្លាំងស្ទើរលោយស្បែកជើង ពេលបាតជើងប៉ះទៅលើថ្មលំកៅស៊ូនោះ ។ នេះជាការពិសោធន៍កាលយើងនៅជាសមណនិស្សិត ធ្វើដំណើរពីវត្តឧណ្ណាលោមទៅសិក្សានៅពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ ។ នៅពេលធ្វើបឋមសង្គាយនាមហាសន្និបាតព្រះសង្ឃបានបន្ទោសព្រះអានន្ទថា មិនបានទូលសួរព្រះពុទ្ធឲ្យបានច្បាស់ថា ទៅអនាគតឲ្យភិក្ខុសង្ឃដកសិក្ខាបទដែលនាំឲ្យមានអាបត្តិខ្លះ តើសិក្ខាបទណាខ្លះដែលត្រូវដក ។ ដោយភាពពុំច្បាស់នេះហើយ ទើបអង្គប្រជុំសង្គាយនាសំរេចរក្សាទុកសិក្ខាបទទាំងអស់ មិនហ៊ានដកសិក្ខាបទមួយណាឡើយ ។ ចំពោះបញ្ហាពាក់ទ្រនាប់ជើងនេះ បើពាក់ដើម្បីការពារកុំឲ្យមេរោគចូលតាមបាតជើង ការពារកុំឲ្យក្ដៅបាតជើង ការពារកុំឲ្យមុតបាតជើងពេលជាន់លើវត្ថុដែលត្រូវមុត ការពារកុំឲ្យជាន់ទីក្រខ្វក់ជាដើម តើគួរពាក់ឬទេ ? ព្រោះការពាក់នេះដើម្បីការពារហេតុការណ៍ដែលបានពោលមកនេះ ពុំមែនដើម្បីលំអដែលជាចំណីនៃតណ្ហាទេ ។ គ្រប់សិក្ខាបទទាំងអស់ដែលព្រះអង្គបញ្ញត្តិ គឺការពារកុំឲ្យចិត្តត្រេកអរនេះឯង ។ បើបាំងឆ័ត្របាន ការពាក់ទ្រនាប់ជើងក៏បាន ព្រោះបាំងឆ័ត្រដើម្បីការពារកុំឲ្យក្ដៅនិងការពារកុំឲ្យទទឹកភ្លៀង ឯការពាក់ទ្រនាប់ជើងដើម្បីការពារដូចបានពោលមកហើយ ។ ការជិះយានយន្តគ្រប់ប្រភេទ ដូចជារថយន្ត អាកាសយានជាដើម ក៏មិនអាចជិះបាន ព្រោះគ្មានពុទ្ធានុញ្ញាត ប៉ុន្តែបើធ្វើកិច្ចដោយតាំងចិត្តថា បើអាត្មាអញមិនជិះ ធ្វើដំណើរដោយថ្មើជើង ដើរផ្លូវឆ្ងាយនិងមានជម្ងឺ កាលបើជិះដោយតាំងចិត្តដូច្នេះមិនត្រូវទោសឡើយ ព្រោះវិន័យកន្ទែងខ្លះជម្រៅដោយកិច្ច «កិច្ចគម្ពីរោ វិនយោ» ។ ដូច្នេះបើព្រះសង្ឃណាពាក់ទ្រនាប់ជើង អ្នកដទៃទៀតមិនត្រូវរិះគន់ឡើយ ព្រោះសេចក្ដីបរិសុទ្ធនិងសៅហ្មងពុំមែនស្ថិតនៅលើការពាក់ទ្រនាប់ជើង ឬមិនពាក់នោះឡើយ គឺស្ថិតនៅលើផ្លូវចិត្តវិញទេ ។ ពេលគេនិមន្តទៅបុណ្យ អង្គដែលមិនពាក់ទ្រនាប់ជើង ឲ្យគេយកទឹកមកលាងព្រះបាទ ព្រោះបើមិនលាងទេ គង់ទៅនឹងប្រឡាក់ពូកកន្ទេលព្រំរបស់គេ ចំណែកព្រះសង្ឃដែ

លពាក់ទ្រនាប់ជើង ឬទ្រនាប់ព្រះបាទវិញ និមន្តទៅគង់តែម្តង មិនបាច់ឲ្យគេលាងព្រះបាទឡើយ ។

## ការកាន់បច្ច័យ

ការកាន់បច្ច័យក្នុងទីនេះ គឺការកាន់ប្រាក់ដែលភាសាខ្មែរនិយាយថាកាន់លុយ ។ នៅក្នុងព្រះវិន័យបានចែងថា ព្រះភិក្ខុត្រេកអរកាន់មាសនិងប្រាក់ ហើយទុកដាក់ជារបស់ខ្លួន ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយៈ ។ អាបត្តិបាចិត្តិយៈមានទោសធ្ងន់ជាងអាបត្តិទុក្កដបន្តិច ។ ត្រូវលះបង់ទើបសំដែងអាបត្តិដាច់ ។ គោលបំណងនៃសិក្ខាបទនេះ គឺដើម្បីសន្តិសុខផ្ទាល់ខ្លួនភិក្ខុ ព្រោះបើភិក្ខុកាន់មាសប្រាក់ ខ្លាចចោរលួចចោរប្លន់ធ្វើបាបដល់ភិក្ខុ និងដើម្បីដកចិត្តកុំឲ្យជាប់ចិត្តក្នុងអាមិសវត្ថុទាំងនេះ ។ បញ្ហាកាន់បច្ច័យនេះប្រទេសដែលកាន់ព្រះពុទ្ធសាសនាថេរវាទដូចគ្នា មានប្រទេសកម្ពុជា លាវ ភូមា ថៃ ស្រីលង្កាជាដើម មិនអាចលះបង់បានឡើយ គឺព្រះសង្ឃនៅតែកាន់ដូចគ្នា វៀរលែងតែព្រះសង្ឃខ្លះដែលមានអ្នកឧបត្ថម្ភក៏មានវេយ្យាវច្ចករ ទើបអាចវៀរបាន ដូចជាព្រះសង្ឃចំរើនសមាធិនិងវិបស្សនានៅអាស្រមខ្លះ ។ ព្រះសង្ឃសមណសិស្សនិងសមណនិស្សិតដែលសិក្សាក្នុងពុទ្ធិកវិទ្យាល័យនិងពុទ្ធិកសកលវិទ្យាល័យនៅតាមទីក្រុងមានទីក្រុងភ្នំពេញជាដើម មានការពិបាលក្នុងការរស់នៅ មិនថាបច្ច័យប្រាក់កាសគេមិនសូវប្រគេនទេ សូម្បីចង្ហាន់បិណ្ឌបាត្រ ក៏គេមិនសូវប្រគេនដែរ ។ ដូច្នេះព្រះសង្ឃទាំងនោះ ខ្វះអ្នកឧបត្ថម្ភ ខ្វះវេយ្យាវច្ចករ មិនអាចលះបង់ការមិនកាន់បច្ច័យបានទេ ។ លោកបានទទួលបច្ច័យខ្លះតាមញាតិញោមប្រគេន គ្រាន់ចំណាយជិះម៉ូតូទៅរៀនបើសាលានៅឆ្ងាយ និងជាវបន្លែបន្លាខ្លះមកធ្វើចង្ហាន់ ។ គោលបំណងនៃការបង្កើតប្រាក់ចាយ គឺដើម្បីស្រណុកដោះដូរទំនិញនិងការចាយវាយផ្សេងៗ ។ មិនថាតែព្រះសង្ឃអ្នកសិក្សាទេ សូម្បីព្រះសង្ឃខ្លះដែលត្រូវធ្វើដំណើរទៅទីឆ្ងាយ មិនអាចយកវេយ្យវច្ចករទៅជាមួយនាំឲ្យអស់ប្រាក់មួយជាពីរឡើយ ។ សម្តេចព្រះសង្ឃរាជជួន-ណាត កាលនៅព្រះជន្មមានព្រះសង្ឃដីកាថា ព្រះសង្ឃមើលទៅមិនអាចលះបង់ការកាន់បច្ច័យបានទេ បើយោលទៅតាមសង្គម

មនុស្សដែលយកប្រាក់កាសនេះជាមូលដ្ឋានក្នុងការចាយវាយ ហើយព្រះសង្ឃពុំមានអ្នកបំរើសព្វគ្រប់ ។ បើយោលតាមព្រះសង្ឃដីកានេះ បើព្រះសង្ឃអង្គណាមានអ្នកបវារណាជួយឧបត្ថម្ភសព្វបែបយ៉ាងហើយ មិនចាំបាច់កាន់បច្ច័យឡើយ ។ ព្រះសង្ឃភាគច្រើនដែលមិនមានលទ្ធភាពធ្វើបានដូច្នេះ អ្នកដទៃទៀតមិនត្រូវរិះគន់ឡើយ ព្រោះសេចក្តីបរិសុទ្ធពុំមែនស្ថិតនៅតែការមិនកាន់បច្ច័យនេះទេ ។ មួយទៀត បើមិនកាន់ខ្លួនឯង ប៉ុន្តែចិត្តនៅកត់សម្គាល់និងត្រេកអរ ក៏មិនខុសគ្នាពីព្រះសង្ឃកាន់បច្ច័យដែរ ។

ចំពោះអ្នកអធិប្បាយធម៌ដែលមានភេទជាគ្រហស្ថ មិនគួរនិយាយអំពីវិន័យរបស់ព្រះសង្ឃទេ ទុកឲ្យព្រះសង្ឃដោះស្រាយវិន័យជាមួយគ្នាលោក ។ ការនិយាយប៉ះពាល់ដល់ព្រះសង្ឃរាប់ម៉ឺនអង្គ ជាការបំបែកសង្គមព្រះសង្ឃខ្មែរឲ្យបែកបាក់គ្នា និងនាំឲ្យពុទ្ធបរិស័ទជាគ្រហស្ថបែកបាក់គ្នា ជាអំពើដែលត្រូវចៀសវាង ដូចជានិយាយថា ប្រគេនបច្ច័យដល់លោក ដូចជាប្រគេនភ្លើងដល់លោកជាដើម ។ សំដីនេះពុំមែនជាការពិតឡើយ ព្រោះបច្ច័យដែលជាប្រាក់នេះ ជាតម្លៃនៃបច្ច័យ៤ លោកអាចយកទៅប្រើប្រាស់សំរាប់ទំនុកបំរុងជីវិតព្រះសង្ឃឲ្យរស់នៅ ដើម្បីសិក្សារៀនសូត្រនិងប្រព្រឹត្តព្រហ្មចរិយាធម៌ ព្រោះប្រាក់កាសនេះជាតំណាងនៃបច្ច័-យ៤គឺ ចីវរបច្ច័យ, បិណ្ឌបាត្របច្ច័យ សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យ ។ ពុំមែនប្រគេនប្រាក់នេះដល់ព្រះសង្ឃហើយ លោកយកទៅបោះចោល ឬយកប្រាក់នេះទៅសាងអំពើបាបឡើយ ផ្ទុយទៅវិញ លោកយកទៅសាងចំណេះដឹង ដូចជាព្រះសង្ឃសមណនិស្សិតដែលកំពុងសិ-ក្សាជាដើម ។ មិនថាតែមាសប្រាក់ដែលព្រះពុទ្ធមិនឲ្យត្រេកអរទេ សូម្បីវត្ថុជាបច្ច័យ៤មានចីវរបច្ច័យជាដើម ក៏ព្រះពុទ្ធមិនឲ្យជាប់ចិត្តដែរ ដូចធម៌អជ្ជៈដែលព្រះសង្ឃពិចារណារាល់ពេលទទួល និងរាល់ពេលប្រើប្រាស់និងបរិភោគនូវបច្ច័យ៤ ដូចពិចារណាចីវរបច្ច័យថា គ្រាន់តែដើម្បីបិទបាំងកេរ្តិ៍ខ្មាស់ ការពារកុំឲ្យរបោមមូសទិចឬខាំ ។ ពិចារណាបិណ្ឌបាត្របច្ច័យថា គ្រាន់តែដើម្បីទ្រទ្រង់រាងកាយឲ្យរស់នៅ ដើម្បីប្រព្រឹត្តព្រហ្មចរិយា-ធម៌ប៉ុណ្ណោះជាដើម ។ ដូច្នេះពុទ្ធបរិស័ទខ្មែរដែលប្រគេនបច្ច័យដែលជាប្រា

ក់ដល់ព្រះសង្ឃ ពុំមែនទាស់ខុសអ្វីឡើយ ដោយលោកពុំមានវេយ្យាវច្ចករ ផ្ទុយទៅវិញរមែងបានបុណ្យកុសលវិញទេ ដូចសេចក្ដីដែលបានពោលមកហើយ ។ សូមអ្នកនិយាយពិចារណាឲ្យវែងឆ្ងាយ កុំយកទោសបន្តិចបន្តួចមកវាយប្រហារព្រះសង្ឃ ។ បើអស់អ្នកបួស គឺអ្នកបួសមិនអាចរស់នៅបាន ព្រះពុទ្ធសាសនាក៏ត្រូវរលាយ ។៚

❄ ❄

❄